# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

# សេចក្ដីអំពាវនាវ

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ជាខួបគម្រប់ ៦៩ឆ្នាំ (**០៤.៦.១៩៤៩ - ០៤.៦.២០១៨**) នៃថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យអាណានិគមវៀតណាមត្រួតត្រាបន្តរហូតសព្វថ្ងៃ គឺជាថ្ងៃឈឺចាប់បំផុតក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិខ្មែរ។ ចាប់ពីពេលនោះមកអាជ្ញាធរអាណានិគមវៀតណាមបានប្រើគ្រប់មធ្យោបាយដើម្បីរំលាយពូជសាសន៍ និងព្រះពុទ្ធសាសនាខ្មែរនៅទីនោះយ៉ាងឃោរឃៅព្រៃផ្សៃបំផុត។

ផ្ដើមចេញពីការជិះជាន់ធ្វើបាបឥតត្រាប្រណីនេះ ការតស៊ូដ៏មោះមុតរបស់ប្រជារាស្ត្រខ្មែរក៏បានចាប់ផ្ដើមឡើងគ្រប់សម័យកាល បានក្លាយជាខ្សែសង្វាក់ជាប់មិនដាច់រហូតបច្ចុប្បន្ន ដើម្បីការពារអត្តសញ្ញាណជាតិ សិល្បៈ វប្បធម៌ អក្សរសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណីនិងព្រះពុទ្ធសាសនាខ្មែរនៅទីនោះ។

ដើម្បីសម្ដែងនូវកតញ្ញូតាធម៌ និងគារវកិច្ច ចំពោះព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ វិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិ ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិ សាសនា និងមាតុភូមិខ្មែរ ជាពិសេសមាតុភូមិខ្មែរកម្ពុជាក្រោម អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ បានរៀបចំធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១.៩៤៩អង្គនិងប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរ ៤ ខែមិថុនា ជារៀងរាល់ឆ្នាំ។

សេចក្ដីដូចបានជម្រាបជូនខាងលើ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរដើម្បីប្រជាធិបតេយ្យ សូមលំឱនកាយគោរពអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាម ព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភ ដូចជាចង្ហាន់ព្រះសង្ឃ ទឹកបរិសុទ្ធ ឬជាថវិកា ដើម្បីយើងខ្ញុំព្រះករុណាយើងខ្ញុំមានលទ្ធភាពរៀបចំពិធីបុណ្យឲ្យបានជោគជ័យដូចរៀងរាល់ឆ្នាំតាមការគួរ។

សេចក្ដីអំពាវនាវនេះ ទុកជាសេចក្ដីគោរពនិមន្ត និងអញ្ជើញព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាមខ្មែរទាំងអស់ ព្រះមេត្តានិងមេត្តានិមន្ត និងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ ដើម្បីញ៉ាំងកម្មវិធីបុណ្យប្រវត្តិសាស្ត្រនេះឲ្យមានសភាពឱឡារិកអធិកអធម និងប្រកបដោយជោគជ័យ ព្រមទាំងចាប់យកមគ្គផលកុសលបុណ្យរៀងៗអង្គនិងខ្លួន កុំបីអាក់ខានឡើយ។

កម្មវិធីបុណ្យនឹងប្រព្រឹត្តទៅនៅទីស្នាក់ការសហគមន៍ខ្មែរកម្ពុជាក្រោម សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា គ.ស.២០១៨ ចាប់ពីម៉ោង ៧:៣០នាទីព្រឹក រហូតដល់ម៉ោង ១១ថ្ងៃត្រង់ និងមានរាប់បាត្រព្រះសង្ឃ ដារបង្សុកូលឧទ្ទិសកុសលជាកិច្ចបង្ហើយបុណ្យ៕

សូមអរព្រះគុណ និងអរគុណ!

រាជធានីភ្នំពេញ, ថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹងថ្ងៃទី០៧ ខែឧសភា គ.ស.២០១៨

**កន្លែងទទួល**
**ទូរស័ព្ទលេខ**
០១២ ៩០៨ ៨៨២
០៨៧ ៩៩៩ ៥៩៨
០១២ ៨៨០ ៣៨៨

ប្រធានគណៈកម្មការបុណ្យ

**ថាច់ សេដ្ឋា**
នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម
អតីតសមាជិកព្រឹទ្ធសភា

**នៅទ្វីបអាមេរិកខាងជើង:**

| | |
|---|---|
| លោក គិម សកល | ៩៧៨.៥៩៦.៥១២៦ |
| លោក គិម វុឌ្ឍី | ៨៦៤.៤៩៤.១៩៩១ |
| លោក គិម សារេត | ៩៧៨.៣២៨.៤៤៣៥ |
| លោក សឺន ស៊ីណា | ២៦៧.២៤២.៣៦០៨ |
| លោក វិញ ថន | ៩០៩.៤៧១.៣៤៩២ |

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅសហរដ្ឋអាមេរិក ប្រទេសកាណាដា ទ្វីបអឺរ៉ុប ប្រទេសអូស្ត្រាលី ប្រទេសនូហ្សេឡិន្ត ព្រមទាំងបណ្ដាប្រទេសនានា សូមមេត្តាផ្ញើសែករូបិយវត្ថុទៅលោក ថាច់ រ៉ា តាមអាសយដ្ឋាននៅខាងក្រោម៖*

For residents of U.S., Canada, Europe, Australia, New Zealand and other countries, please kindly make payable personal check, traveler's check or money order and send it to:

**RA THACH**
P.O. BOX 37502
PHILADELPHIA, PA 19148
U.S.A.

សូមថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុន។

Thank you very much for your charity in advance.

---